រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ: ០៩៥/១៥ ស.ប.ក អ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០១៥

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១៥
## និងទិសដៅការងារ ខែតុលា ឆ្នាំ២០១៥
(ពីថ្ងៃទី២៦/៨/២០១៥ - ២៥/៩/២០១៥)

អនុវត្តតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពីខែសីហា ឆ្នាំ២០១៥ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងគោលដៅចូលរួមចំណែកអនុវត្ត គោលនយោបាយភូមិឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពជូនប្រជាពលរដ្ឋ ។ តាមរយៈការអនុវត្តផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន នៅក្នុងខែកញ្ញានេះ យើងបានកត់សម្គាល់ទៅលើសភាពការណ៍គ្រឿងញៀនមួយចំនួន និងអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

នៅក្នុងខែកញ្ញានេះ អគ្គស្នងការដ្ឋាននគរបាលជាតិ, បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស, មន្ទីរប្រឆាំងគ្រឿងញៀន ព្រមទាំងបណ្តាស្នងការដ្ឋាននគរបាល, បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ចំនួន ២៤ លើ ២៥ រាជធានី ខេត្ត (លើកលែងខេត្តមណ្ឌលគិរី) បានបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ទទួលបានលទ្ធផលគួរកត់សម្គាល់ ។ ក្នុងនោះ មានបទល្មើសចរាចរជួញដូរនូវប្រភេទគ្រឿងញៀនសំយោគ មេតំហ្វេតាមីន ICE និង WY ២ករណី ដែលបង្ក្រាបដោយកម្លាំងរបស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង ដោយចាប់យកមេតំហ្វេតាមីន ICE និង WY ប្រមាណ ៧០៣,៦២ ក្រាម និងឃាត់ខ្លួនជនសង្ស័យជនជាតិឡាវ ១នាក់ (ប្រុស) ។

តាមរយៈការបង្ក្រាបបានបង្ហាញថា ក្រុមឈ្មួញនៅតែបន្តសកម្មភាពនាំគ្រឿងញៀនពីតំបន់ត្រីកោណមាស ឆ្លងកាត់តាមប្រទេសឡាវ ចូលមកកម្ពុជាតាមបណ្តាច្រកនៃខេត្តនៅភាគឦសាន ក្នុងគោលដៅផ្គត់ផ្គង់តម្រូវការក្នុងស្រុកមួយចំនួន និងមួយចំនួននាំទៅកាន់ប្រទេសទីបី ។ ជាក់ស្តែងនៅរាជធានីភ្នំពេញ សមត្ថកិច្ចនគរបាលបង្ក្រាបបាន ៤៧ ករណីបទល្មើសគ្រឿងញៀន និងឃាត់ខ្លួនជនសង្ស័យ ១៨១ នាក់ ក្នុងនោះ មានជនសង្ស័យ ៨០ នាក់ ត្រូវបាននគរបាលខណ្ឌសែនសុខ ឃាត់ខ្លួននៅក្នុងយុទ្ធនាការបន្តបង្ក្រាបបទល្មើសគ្រឿងញៀន នៅតំបន់ភូមិបឹងឈូក ក្នុងសង្កាត់ទឹកថ្លា ។

## II. អំពីការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តដឹកនាំ និងណែនាំលើការងារជាគោលសំខាន់ៗ មានដូចជា ៖

- ជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តគោលដៅ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមធ្វើសកម្មភាពផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងឱកាសបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ
- ដំណើរការផលិតស្ទីកឃ័រ (Sticker) អប់រំពីបញ្ហាគ្រឿងញៀន ដើម្បីផ្សព្វផ្សាយនៅតាមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍, ច្រកទ្វារព្រំដែនអន្តរជាតិ និងបណ្តាលខេត្តគោលដៅ ដោយសហការជាមួយក្រសួងទេសចរណ៍ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- សហការជាមួយភាគីឡាវ ដើម្បីរៀបចំឯកសារអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន ជាភាសាកម្ពុជា ឡាវ និងរៀបចំកសាងភូមិ ឃុំតាមព្រំដែននៃប្រទេសទាំងពីរ គ្មានគ្រឿងញៀន
- បន្តកែសម្រួល និងពង្រឹងសមត្ថភាព គុណភាព នៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប និង ព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តពង្រីកកម្មវិធីព្យាបាលដោយផ្អែកលើសហគមន៍ ដោយរៀបចំយន្តការដាក់លាក់តាមខ្លឹមសារបីគឺ ការព្យាបាល ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើសមាហរណកម្ម
- បន្តការរៀបចំស្លាកសញ្ញា ដែលមានខ្លឹមសារផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយឥតគិតថ្លៃ ដើម្បីដាក់បង្ហាញនៅតាមមន្ទីរពេទ្យបង្អែក-មណ្ឌលសុខភាព ដែលបានរៀបចំបំពាក់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនរួចនៅក្នុងរាជធានីភ្នំពេញ និងបន្តជំរុញកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅរាជធានីភ្នំពេញឱ្យកាន់តែមានគុណភាព
- បន្តធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីកម្មវិធីផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព និងការអនុវត្តកម្មវិធីម្ទុល/ស៊ីរ៉ាំងនៅកម្ពុជា
- បន្តធ្វើសម្រង់បទល្មើសនានា ដែលកើតឡើងដោយសារការប្រើប្រាស់គ្រឿងញៀន, បទល្មើសគ្រឿងញៀន នៅតាមសាលាដំបូងរាជធានី ខេត្ត និងជនសង្ស័យពាក់ព័ន្ធបទល្មើសគ្រឿងញៀន ដោយបញ្ជាក់ពីមុខរបរច្បាស់លាស់សម្រាប់ នព្វមាស ឆ្នាំ២០១៥
- ត្រៀមធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនខេត្តភាគពាយ័ព្យសាន និងកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ឡាវ លើកទី១
- បន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បង្កើតក្រុមការងារដើម្បីសិក្សាស្វែងយល់ពីនីតិវិធីពាក់ព័ន្ធនឹងការរឹបអូសទ្រព្យ ដែលបានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ពីប្រទេសជិតខាង
- បន្តជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តជំរុញការរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការតែងតាំងសមាសភាពរបស់គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បានចុះហត្ថលេខា បន្តគម្រោង " ភាពជាដៃគូនៃមន្ត្រីអនុវត្តន៍ច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងឧក្រិដ្ឋកម្មគ្រឿងញៀន" (PATROL) ដំណាក់កាលទី២ (២០១៥-២០១៧)
- បានជួបជាមួយស្ថាបនិកអង្គការមេជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលអាស៊ីអាគ្នេយ៍កម្ពុជា ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងគម្រោង រួមគ្នាអភិវឌ្ឍន៍ខេត្តបន្ទាយមានជ័យ ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

- **ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ៖**
  - ក្នុងខែកញ្ញានេះ តំណាងអធិការដ្ឋាននគរបាលខណ្ឌសែនសុខ និងខណ្ឌច្បារអំពៅ បានផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ CNC ក្នុងកម្មវិធី ៖
    - ***ព័ត៌មានពេលថ្ងៃ*** ក្រោមប្រធានបទស្តីពី សកម្មភាព និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ក្នុងភូមិសាស្ត្រខណ្ឌសែនសុខ (២៣.៩.២០១៥)
    - ***សភាអ៊ីនធឺណែត*** ក្រោមប្រធានបទស្តីពី សកម្មភាព និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ក្នុងភូមិសាស្ត្រខណ្ឌច្បារអំពៅ (២៣.៩.២០១៥) ។ ជាមួយនេះ
  - គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តដទៃទៀត ក៏បានបញ្ជ្រាបខ្លឹមសារអប់រំ និងផ្តល់កិច្ចសម្ភាសន៍ពីបញ្ហាគ្រឿងញៀន នៅតាមស្ថានីយវិទ្យុរាជធានី ខេត្តរបស់ខ្លួន ។
- **ការងារអប់រំតាមសហគមន៍**

លើការងារនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងព័ត៌មាន, ក្រសួងមហាផ្ទៃ, ក្រសួងកិច្ចការនារី, ក្រសួងធម្មការនិងសាសនា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងទេសចរណ៍, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងពាណិជ្ជកម្ម ក៏បានធ្វើសកម្មភាពអប់រំពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ តាមវិស័យជំនាញរបស់ខ្លួន ។

ក្រៅពីការអប់រំដោយក្រសួង-ស្ថាប័ន ក៏នៅមានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ០៥ គឺ ខេត្តកណ្តាល, បាត់ដំបង, ស្វាយរៀង, មណ្ឌលគិរី និងខេត្តកំពង់ស្ពឺ បានចុះអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន នៅតាមមូលដ្ឋានរបស់ខ្លួន តាមរយៈកម្មវិធីនិងវេទិកានានា (ដូចមានខ្លឹមសារសកម្មភាពនៅក្នុងតារាងឧបសម្ព័ន្ធទី១) ។

លទ្ធផលជារួម មានមហាជនចូលរួមប្រមាណ **១១៦.៧១០** នាក់ ក្នុងនោះអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមអនុវត្តដូចខាងក្រោម ៖

- ចូលរួមផ្តល់កិច្ចសម្ភាសន៍ កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ ក្នុងកម្មវិធី " វេទិកាអ្នកស្តាប់" វិទ្យុអាស៊ីសេរីក្រោមប្រធានបទស្តីពីយន្តការទប់ស្កាត់ការរីករាលដាលនៃគ្រឿងញៀននៅកម្ពុជា
- បញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀននៅក្នុងកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយប្រធានបទ រួមគ្នាគោរព និងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក នៅកម្ពុជា របស់ក្រុមហ៊ុនហូមមេឌា
- ចូលរួមក្នុងកម្មវិធីប្រឡងផ្កាច់ព្រ័ត្រ និងបិទមហោស្រពតន្ត្រី ចម្រៀងសម័យ ថ្នាក់ជាតិ ឆ្នាំ ២០១៥ ដែលរៀបចំដោយក្រសួងព័ត៌មាន
- ចូលរួមធ្វើបទបង្ហាញស្តីពីបញ្ហាគ្រឿងញៀន ក្នុងសិក្ខាសាលាពង្រឹងសមត្ថភាពស្តីពីលក្ខខណ្ឌការងារ វិធានការអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ផ្នែកសេវាកម្សាន្ត ដល់ក្រុមអធិការកិច្ចការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តស្ទឹងត្រែង និងក្រុមហ៊ុនហូមមេឌា ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន ក្នុងកម្មវិធីប្រគំតន្ត្រីតាំងពិព័រណ៍ផលិតផលកម្ពុជា-ថៃ

- បញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងកម្មវិធីប្រគំតន្ត្រីសប្បុរសធម៌លើកស្ទួយជនពិការ ដែលរៀបចំនៅខេត្តកណ្តាល, ខេត្តតាកែវ, ខេត្តកំពង់ឆ្នាំង, ខេត្តពោធិ៍សាត់
- បាននិងកំពុងបន្តកិច្ចសហការជាមួយអង្គការមិត្តសម្លាញ់ ក្នុងការរៀបចំផលិតផ្ទាំងរូបភាពផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន
- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែកញ្ញា ឆ្នាំ២០១៥ មានអ្នកអានប្រមាណ **៣២.៩៥០** ដង ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

- ចូលរួមវេទិកាប្រឆាំងគ្រឿងញៀនប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ នៅប្រទេសសឹង្ហបុរី (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប)
- ចូលរួមកិច្ចប្រជុំតុមូល ក្រោមប្រធានបទស្តីពី ឱកាសផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញរឹងនិងទន់ ដល់ជនជាប់ឃុំ ព្រមទាំងផ្តល់ជាការងារធ្វើខណៈរួចផុតពីការឃុំឃាំង កាលពីថ្ងៃទី០៤ខែកញ្ញាឆ្នាំ២០១៥ ដែលរៀបចំដោយគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម "The International Committee of the Red Cross. ICRC" (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប)
- ចូលរួមផ្តល់យោបល់នៅក្នុងកិច្ចប្រជុំសម្របសម្រួលស្តីពី កញ្ចប់សេវាច្បាប់នៅក្នុងបរិបទមេរោគអេដស៍ និងកិច្ចសន្ទនានៃអ្នករស់នៅជាមួយអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រឈមមុខខ្ពស់ ដែលរៀបចំដោយវេទិកាហ្វុនប៉ាម កាលពីថ្ងៃទី១៧-១៨ ខែកញ្ញា ឆ្នាំ២០១៥ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប, មន្ត្រីសរុប ៥៥ រូប)
- ចូលរួមកិច្ចប្រជុំសម្របសម្រួលជាមួយដៃគូអនុវត្តគម្រោងកាត់បន្ថយគ្រោះថ្នាក់ ប្រចាំខែកញ្ញា ឆ្នាំ២០១៥ កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ដែលរៀបចំដោយក្រសួងសុខាភិបាល (មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប)

### ២.២. ការព្យាបាល និងស្តារនីតិសម្បទា

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី២៤-៣១ ខែសីហា ឆ្នាំ២០១៥ នៅប្រទេសថៃ (ដោយមន្ត្រីក្រសួងសុខាភិបាល)
- ចូលរួមកិច្ចប្រជុំពិនិត្យ កែសម្រួលបញ្ចប់មគ្គុទេសក៍គ្លីនិកសម្រាប់ព្យាបាលដោយឱសថមេតាដូន ចំនួន ០៣ លើកគឺនៅថ្ងៃទី០៤, ថ្ងៃទី០៨ និងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប)
- បានចូលរួមវេទិកាកិច្ចប្រជុំកំពូល ចិន-អាស៊ាន លើកទី៣ ស្តីពីសុវត្ថិភាពឱសថ កាលពីថ្ងៃទី ១៨-១៩ ខែកញ្ញា ឆ្នាំ២០១៥ នៅប្រទេសចិន (ដោយមន្ត្រីក្រសួងសុខាភិបាល)
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់ លើកទី៣ ស្តីពីការព្យាបាលអ្នកប្រើប្រាស់គ្រឿងញៀនក្នុងមណ្ឌលបង្ខាំង នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក កាលពីថ្ងៃទី២១-២៣ ខែកញ្ញា ឆ្នាំ ២០១៥ ប្រទេសហ្វីលីពីន (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប, មន្ត្រីសរុប ៤ រូប)
- បាននិងកំពុងបន្តអនុវត្តកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍

នៅក្នុងមន្ទីរពេទ្យបង្អែក ៧ កន្លែង, មណ្ឌលសុខភាព ១៣ កន្លែង និងប៉ុស្តិ៍សុខភាព ១ កន្លែង របស់មន្ទីរសុខាភិបាលរាជធានីភ្នំពេញ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

- បានទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យបទល្មើសគ្រឿងញៀនប្រចាំឆ្នាំ២០១៥ កាលពី ថ្ងៃទី៣១ ខែសីហា ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៥ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប)
- ចូលរួមសិក្ខាសាលាស្តីពីការវិភាគ, ការរៀបចំរបាយការណ៍ និងការអភិវឌ្ឍនៃគ្រឿងញៀនសំយោគជាលក្ខណៈសកល (Global Synthetics Monitoring: Analyses, Reporting and Trends (SMART) Programme ប្រចាំតំបន់ កាលពីថ្ងៃទី១៦-១៧/៩/២០១៥ នៅទីក្រុងប៉េកាំង ប្រទេសចិន
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីកិច្ចសហប្រតិបត្តិការឆ្លងដែនរវាង កម្ពុជា-ឡាវ កាលពីថ្ងៃទី ២១-២៥ ខែកញ្ញាឆ្នាំ២០១៥ នៅស្នាក់ការការិយាល័យ BLO ត្រពាំងក្រៀល ខេត្តស្ទឹងត្រែង ដែលរៀបចំដោយអង្គការ UNODC ប្រចាំតំបន់
- បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) បានចំនួន ០២ វគ្គបន្ថែមទៀត ដែលមានមន្ត្រីអនុវត្តន៍ច្បាប់ចូលរួមសរុប **២៣** នាក់ គឺ ៖
  - វគ្គទី៩/ឆ្នាំ២០១៥ ពីថ្ងៃទី១៤-១៨ ខែកញ្ញា ឆ្នាំ២០១៥ ដល់មន្ត្រីនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ចំនួន ១២ នាក់
  - វគ្គទី១០/ឆ្នាំ២០១៥ ពីថ្ងៃទី២៨ ខែកញ្ញា ដល់ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៥ ដល់មន្ត្រីនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចំនួន ១១ នាក់
- ចូលរួមផ្តល់បទបង្ហាញពាក់ព័ន្ធនឹងគម្រោងស្តីពី ភាពជាដៃគូនៃមន្ត្រីអនុវត្តន៍ច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែននិងឧក្រិដ្ឋកម្មគ្រឿងញៀន (PATROL) ក្នុងសិក្ខាសាលា បណ្តុះបណ្តាលរបស់ក្រសួងបរិស្ថានស្តីពីការអង្កេតនិងត្រួតពិនិត្យ សារធាតុបំផ្លាញស្រទាប់អូហ្សូន កាលពីថ្ងៃទី១៤-១៥ ខែកញ្ញា ឆ្នាំ២០១៥
- បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ តាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (E-Learning) ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន ពីថ្ងៃទី២០-២៦ ខែកញ្ញា ឆ្នាំ២០១៥ នៅខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ សរុប **២៥** នាក់
- ចូលរួមវគ្គបណ្តុះបណ្តាលចំនួន ០២ វគ្គ ដែលរៀបចំដោយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ គឺ ៖
  - វគ្គបណ្តុះបណ្តាលស្តីពីការវិភាគគ្រឿងញៀន តាមបច្ចេកទេស TLC នៅប្រទេសថៃ ពីថ្ងៃទី៣០ ខែសីហា ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៥ ដែលចូលរួមដោយមន្ត្រីនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ចំនួន ០៤ រូប
  - វគ្គបណ្តុះបណ្តាលស្តីពីការវិភាគគ្រឿងញៀន តាមម៉ាស៊ីន GC នៅប្រទេសថៃ ពីថ្ងៃទី៣០

ខែសីហា ដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៥ ដែលចូលរួមដោយមន្ត្រីអគ្គលេខាធិការដ្ឋាន ចំនួន ០២ រូប

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀន សរុប **៣១១** ករណី លើ ២៨០ ករណី នៃខែសីហា ឆ្នាំ២០១៥
- ឃាត់ខ្លួនជនសង្ស័យ សរុប **៨១០** នាក់ (ស្រី ៨៣ នាក់) លើ ៦៤៦ នាក់ នៃខែសីហា ឆ្នាំ ២០១៥

  ក្នុងបទល្មើសគ្រឿងញៀន ៣១១ ករណី និងជនសង្ស័យ ៨១០ នាក់ ខាងលើគឺ ៖
  - បទល្មើសគ្រឿងញៀនបង្ក្រាបដោយ សមត្ថកិច្ចនគរបាលជាតិ **២៣៨** ករណី, ជនសង្ស័យ **៥៩៦** នាក់ (ស្រី ៥៦ នាក់)
  - បទល្មើសគ្រឿងញៀនបង្ក្រាបដោយ សមត្ថកិច្ចកងរាជអាវុធហត្ថ **៧៣** ករណី, ជនសង្ស័យ **២១៤** នាក់ (ស្រី ២៧ នាក់)
- ក្នុងចំនួនជនសង្ស័យ ៨១០ នាក់ ខាងលើមាន ៤ សញ្ជាតិគឺ ខ្មែរ ៨០២ នាក់ (ស្រី ៨២ នាក់), វៀតណាម ០៥ នាក់ (ស្រី ០១ នាក់), ថៃ ០១ នាក់ (ប្រុស), ឡាវ ០១ នាក់ (ប្រុស), អេស្ប៉ាញ ០១ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត
- វត្ថុតាងគ្រឿងញៀនចាប់យក ៖ មេតំហ្វេតាមីនក្រាមម្សៅ(ICE) ១ ^គ.ក្រ^ ៧៤៧ ^ក្រាម^ ៣៨, មេតំហ្វេតាមីន (WY) ២៦២,៥៤ ^ក្រាម^ សារធាតុសង្ស័យគ្រឿងញៀន ៥៧,៥៣ ^ក្រាម^
- ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានចាប់យក ៖ ម៉ូតូ ១២៥ ^គ្រឿង^ រថយន្ត ៥ ^គ្រឿង^ ប្រាក់កម្ពុជា ១៤.១៤៩.១០០ ^រៀល^ ប្រាក់ថៃ ២.៤៥០ ^បាត^ ប្រាក់អាមេរិក ២.០២១ ^ដុល្លារ^ (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣)
- ជនសង្ស័យចាប់តាមដីកា មាន ២១ ដីកា = មនុស្ស ១៨ នាក់ (ស្រី ០១ នាក់) ជនជាតិខ្មែរ

### ៣.៣. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

- សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសល្យវិច័យក្នុងខែកញ្ញា ឆ្នាំ២០១៥ សរុប ២០៨ សំណាក = ១៨១ ករណី ក្នុងនោះ ៖
  - សំណាកវិជ្ជមានសារធាតុញៀន មាន ១៨៨ សំណាក = ១៧៥ ករណី គឺ ៖
    - មេតំហ្វេតាមីន ICE ១៥៧ សំណាក = ៧៥,៤៨ %
    - មេតំហ្វេតាមីន WY ២៣ សំណាក = ១១,០៥ %
    - កូកាអ៊ីន ០២ សំណាក = ០,៩៦ %
    - តេត្រាអ៊ីដ្រូកានណាប៊ីណុល ០៥ សំណាក = ២,៤០ %
    - កេតាមីន ០១ សំណាក = ០,៤៨ %
  - សំណាកអវិជ្ជមានសារធាតុញៀន ២០ សំណាក = ០៦ ករណី

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- បានដកស្រង់ទិន្នន័យសារធាតុគីមីផ្សំ ដែលពាក់ព័ន្ធនឹងតារាង IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនសរុបមានចំនួន **១.៧៨៦.១៤៥** ^គ.ក្រ^ និង **១២.០០០** ^លីត្រ^ ក្នុងនោះ សារធាតុគីមីផ្សំដែលមាន ៖
  - បទដ្ឋានបច្ចេកទេសឱ្យនាំចូលដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម មាន ១.១៤៦.០០០ ^គ.ក្រ^

- អាជ្ញាប័ណ្ណឱ្យនាំចូលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ៦៤០.១៤៥ គ.ក្រ ១២.០០០ លីត្រ

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន កាលពីថ្ងៃទី២៤ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ នៅទីក្រុងគុនមិញ ប្រទេសចិន (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៦ រូប, មន្ត្រីពាក់ព័ន្ធ ១៥ រូប)
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ កាលពីថ្ងៃទី៣១ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ នៅប្រទេសថៃ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប)

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- ចូលរួមកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៥ តាមការអញ្ជើញរបស់ក្រសួងមហាផ្ទៃ នាថ្ងៃទី២៦-២៨ ខែសីហា ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ
- រៀបចំទទួលគណៈប្រតិភូថៃ (ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌) ដែលអញ្ជើញមកទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី០៩-១០ ខែកញ្ញា ឆ្នាំ២០១៥ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី កម្ពុជា-ថៃ
- ខេត្តព្រះវិហារ បានប្រជុំជាមួយខេត្តចំប៉ាសាក់ ប្រទេសឡាវ (ភាគីឡាវធ្វើជាម្ចាស់ផ្ទះ) ដើម្បីត្រួតពិនិត្យនិងពិភាក្សាលើកំណត់ហេតុនៃកិច្ចប្រជុំលើកទី៥ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការតាមបណ្តោយព្រំដែន ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ទប់ស្កាត់ និងបង្ក្រាបនូវរាល់បទល្មើសគ្រឿងញៀន ការជួញដូរមនុស្ស និងបទល្មើសផ្សេងៗទៀត (ភាគីកម្ពុជាមានអ្នកចូលរួម ១៥ រូប)
- បន្តការត្រៀមលក្ខណៈជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ អញ្ជើញទៅទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- បានជួបពិភាក្សាការងារជាមួយតំណាងវិទ្យាស្ថានអន្តរជាតិ (TNI) ដែលមានស្នាក់ការនៅប្រទេសហូឡង់ដ៍ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ដើម្បីពិភាក្សាអំពីការរៀបចំកិច្ចប្រជុំសន្ទនាក្រៅផ្លូវការអំពីគោលនយោបាយគ្រឿងញៀន ដែលតាមការគ្រោងនឹងមានអ្នកចូលរួមប្រហែល ៣៥ នាក់ មកពីប្រទេសផ្សេងៗ ដោយស្នើសុំឱ្យកម្ពុជា ធ្វើជាម្ចាស់ផ្ទះ ក្រោមការគាំទ្រថវិកាដោយវិទ្យាស្ថានខាងលើ
- បានចូលរួមកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន (ADLOMICO) កាលពីថ្ងៃទី២២-២៤ ខែកញ្ញា ឆ្នាំ២០១៥ នៅសាធារណរដ្ឋកូរ៉េ
- រៀបចំឯកសារ និងត្រៀមបញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលាស្តីពីវិធានការឆ្លើយតបទៅនឹងការគំរាមកំហែងពីគ្រឿងញៀនខុសច្បាប់ក្នុងតំបន់អាស៊ាន (ASEAN Narcotics Cooperation Center. ASEAN-NARCO) ដែលរៀបចំដោយការិយាល័យ នៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ
- ទំនាក់ទំនងជាមួយអង្គការ UNODC ដើម្បីរៀបចំឯកសារ និងត្រៀមចាត់បញ្ជូនមន្ត្រីទៅចូលរួម ៖
  - កិច្ចសន្ទនាថ្នាក់តំបន់ ស្តីពីគោលនយោបាយគ្រឿងញៀន និងផលប៉ះពាល់លើការឆ្លងមេរោគអេដស៍ ដែលនឹងត្រូវប្រព្រឹត្តទៅនាថ្ងៃទី១៤-១៥ ខែតុលា ឆ្នាំ២០១៥ នៅប្រទេសថៃ
  - កិច្ចប្រជុំប្រមុខស្ថាប័នអនុវត្តន៍ច្បាប់គ្រឿងញៀន អាស៊ី-ប៉ាស៊ីហ្វិក (HONLEA) លើកទី៣៩ ដែលនឹងត្រូវរៀបចំនៅទីក្រុងបាងកក ប្រទេសថៃ នាថ្ងៃទី១៩-២២ ខែតុលា ឆ្នាំ២០១៥
  - សិក្ខាសាលាស្តីពីវគ្គបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋានក្នុងការវិភាគគ្រឿងញៀន ដែលនឹងត្រូវរៀបចំនៅប្រទេសសិង្ហបុរី នាថ្ងៃទី២៦-៣០ ខែតុលា ឆ្នាំ២០១៥

- បានទំនាក់ទំនងជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលអាស៊ានសម្រាប់ការងារអប់រំបង្ការគ្រឿងញៀន (ASEAN Training Center for Preventive Drug Education. ATCPDE) ដើម្បីរៀបចំឯកសារ និងត្រៀមចាត់បញ្ជូនមន្ត្រី ទៅចូលរួមវគ្គបណ្តុះបណ្តាលបំណិនជីវិតសម្រាប់ភ្នាក់ងារអប់រំគ្រឿងញៀនអាស៊ាន ដែលនឹងរៀបចំនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន (០៥-០៩/១០/២០១៥)
- បានទំនាក់ទំនងជាមួយក្រសួងមហាផ្ទៃប្រទេសម៉ាឡេស៊ី ដើម្បីរៀបចំឯកសារនិងត្រៀមទៅចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន លើកទី៤ ស្តីពីបញ្ហាគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៧-៣០ ខែតុលា ឆ្នាំ២០១៥ នៅប្រទេសម៉ាឡេស៊ី ។

### ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បាននិងកំពុងបន្តរៀបចំផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានពិនិត្យ និងកែសម្រួលតាមទម្រង់ថ្មីនៃសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមាន ៧ ជំពូក ១៦ មាត្រា កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ និងបានដាក់ជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដើម្បីពិនិត្យ មុននឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី
- បានបន្តការពិនិត្យ និងកែសម្រួលអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានចូលរួមកិច្ចប្រជុំគណៈកម្មការផែនការ និងរបាយការណ៍ជាតិស្តីពីកុមារ កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងចាត់តាំងថ្នាក់ដឹកនាំនាយកដ្ឋាន ០១ រូប ចូលរួមក្នុងគណៈកម្មការការពារកុមារថ្នាក់ជាតិ
- បានរៀបចំកិច្ចប្រជុំត្រៀម កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ សម្រាប់ជួបប្រជុំ ពិភាក្សាការងារជាមួយតំណាងអគ្គមហាអយ្យការអមសាលាឧទ្ធរណ៍ និងសាលាឧទ្ធរណ៍ ពាក់ព័ន្ធនឹងការចោទប្រកាន់អ្នកប្រើប្រាស់គ្រឿងញៀន ឱ្យទៅទទួលយកសេវាព្យាបាល និងស្តារនីតិសម្បទា
- បានបន្តកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាង អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ខេត្តមណ្ឌលគិរី បានប្រជុំត្រួតពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យព័ត៌មានគ្រឿងញៀន តាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ដែលអនុវត្តដោយ ៖
    - អធិការដ្ឋាននគរបាលក្រុងសែនមនោរម្យ (១២ នាក់), ស្រុកអូររាំង(០៩ នាក់), ស្រុកកែវសីមា (១២ នាក់), ស្រុកកោះញែក ( ២៧ នាក់), ស្រុកពេជ្រាដា (១៥ នាក់) **សរុប ៧៥ នាក់**
    - បើកវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ដល់មន្ត្រីនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៦២១ ( ២១ នាក់), វរសេនាតូចលេខ៣០៣ (៤០ នាក់) **សរុប ៦១ នាក់** ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែតុលា ឆ្នាំ២០១៥

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

- ត្រៀមធ្វើសកម្មភាពផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងឱកាសបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តគោលដៅ

- ត្រៀមចុះផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច (ថ្ងៃទី៣០ខែតុលាឆ្នាំ២០១៥) និងនៅតាមវិទ្យាល័យ អនុវិទ្យាល័យក្នុងរាជធានីភ្នំពេញ
- ត្រៀមរៀបចំ និងអញ្ជើញវាគ្មិនជាតំណាងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខណ្ឌដូនពេញ និងខណ្ឌដង្កោ ដើម្បីផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ក្នុងកម្មវិធី ៖
  - ព័ត៌មានពេលថ្ងៃ ក្រោមប្រធានបទស្តីពី ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅក្នុងភូមិសាស្ត្រខណ្ឌដូនពេញ (ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥)
  - សភាអ៊ីនធឺណែត ក្រោមប្រធានបទស្តីពី ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅក្នុងភូមិសាស្ត្រខណ្ឌដង្កោ (ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥)
- បន្តរៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន
- បន្តសហការជាមួយក្រសួងទេសចរណ៍ រៀបចំផែនការសកម្មភាពផ្សព្វផ្សាយនិងបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍គោលដៅនានា
- បន្តសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តគោលដៅ និងបណ្តាក្រុមហ៊ុនឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្ម
- បន្តជំរុញក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមរោងចក្រ និងសហគ្រាស ។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន**

- ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលបំណិនជីវិតសម្រាប់ភ្នាក់ងារអប់រំគ្រឿងញៀនអាស៊ាន ដែលនឹងរៀបចំនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នាថ្ងៃទី០៥-០៩/១០/២០១៥
- ត្រៀមចូលរួមកិច្ចប្រជុំ សន្ទនាថ្នាក់តំបន់ ស្តីពីគោលនយោបាយគ្រឿងញៀន និងផលប៉ះពាល់លើការឆ្លងមេរោគអេដស៍ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៤-១៥ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ
- បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្មថែមទៀត ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាពដែលនៅជិត
- បន្តការកែសម្រួល និងពង្រឹងសមត្ថភាព គុណភាព នៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- បន្តជំរុញក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីពង្រឹងយន្តការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
- ត្រៀមសហការជាមួយក្រសួងសុខាភិបាល ធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយថែមទៀតពីការអនុវត្តកម្មវិធីម្ទុល/ស៊ីរ៉ាំង នៅកម្ពុជា ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់**

- ត្រៀមទៅចូលរួមសិក្ខាសាលា ស្តីពីវិធានការឆ្លើយតបទៅនឹងការគំរាមកំហែងពីគ្រឿងញៀនខុសច្បាប់ក្នុងតំបន់អាស៊ាន (ASEAN-NARCO) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៧-២៩ ខែកញ្ញា ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ
- ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីយោធានៃតំបន់ប្រតិបត្តិការសឹករងខេត្តមណ្ឌលគិរី និងខេត្តកំពង់

ចាម ពីថ្ងៃទី០៥-០៨ ខែតុលា ឆ្នាំ២០១៥

- ត្រៀមចូលរួមសិក្ខាសាលាស្តីពីវគ្គបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋាន ក្នុងការវិភាគគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៦-៣០ ខែតុលា ឆ្នាំ២០១៥ នៅប្រទេសសិង្ហបុរី
- បន្តបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ(CBT)
- បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីនៃកងយោធពលខេមរភូមិន្ទ នៅតាមតំបន់ប្រតិបត្តិការសឹករងខេត្តមណ្ឌលគិរី និងខេត្តកំពង់ចាម
- បន្តបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (E-Learning)
- បន្តជំរុញខេត្តដែលមានការិយាល័យទំនាក់ទំនងព្រំដែន (BLO) រៀបចំពិធីប្រកាសសមាសភាព របស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀន
- បន្តជំរុញក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម
- បន្តប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- ត្រៀមធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀននៅខេត្តភាគឦសាន និងកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ឡាវ លើកទី១
- ត្រៀមចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-វៀតណាម លើកទី៣ ដែលនឹងប្រព្រឹត្តទៅ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម
- បន្តអនុវត្តផែនការសកម្មភាពតាមស្មារតីនៃការព្រមព្រៀងគ្នាស្តីពី កិច្ចសហប្រតិបត្តិការលើការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន (Letter of Agreement) រវាងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB)
- ត្រៀមទទួលគណៈប្រតិភូនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដែលអញ្ជើញមកទស្សនកិច្ចនៅកម្ពុជា (ខេត្តព្រះវិហារ និង ខេត្តស្ទឹងត្រែង)
- សម្របសម្រួលដំណើរទស្សនកិច្ចផ្លូវការជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ដែលដឹកនាំដោយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- ត្រៀមចូលរួមកិច្ចប្រជុំប្រមុខស្ថាប័នអនុវត្តន៍ច្បាប់អាស៊ី-ប៉ាស៊ីហ្វិក (Heads of National Drug Law Enforcement Agencies. HONLEA) លើកទី៣៩ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៩-២២ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ
- ត្រៀមចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន លើកទី៤ ស្តីពីបញ្ហាគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៧-៣០ ខែតុលា ឆ្នាំ២០១៥ នៅប្រទេសម៉ាឡេស៊ី
- បន្តសហការជាមួយអង្គការ UNODC ក្នុងការអនុវត្តបន្តគម្រោង PATROL ដំណាក់កាលទី២

- ត្រៀមចុះទៅពិនិត្យស្ថានភាព ភូមិសាស្ត្រព្រំដែន នៃខេត្តពោធិ៍សាត់ និងខេត្តរតនគិរី ដើម្បីរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO)
- ត្រៀមរៀបចំដំណើរទស្សនកិច្ចជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

- បន្តការរៀបចំផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តរៀបចំសេចក្តីព្រាងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។៕

**អគ្គលេខាធិការ**

**ឧត្តមសេនីយ៍ឯក មាស_វីរិទ្ធ**

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ

  " ដើម្បីជូនជ្រាប "
- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

  " ដើម្បីមុខការ "
- ឯកសារ